

# បច្ចុប្បន្នភាពទីផ្សារ និង ការតាមដានរដូវកាល

ខែមេសា ឆ្នាំ២០២៣

## ប្រទេសកម្ពុជា

កម្មវិធីស្បៀងអាហារពិភពលោកនៃអង្គការសហប្រជាជាតិ សហការជាមួយ
ការិយាល័យទីផ្សារកសិកម្មនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ


**ការិយាល័យទីផ្សារកសិកម្ម (AMO)**
នាយកដ្ឋានផែនការនឹងស្ថិតិ
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មៀច យ៉ាឌី meachyady@gmail.com
គេហទំព័រ: https://amis.maff.gov.kh/

**វិភាគ និងធ្វើផែនទីភាពងាយរងគ្រោះ**
ផ្នែកស្រាវជ្រាវ វិភាគ និងតាមដាននៃកម្មវិធីស្បៀងអាហារពិភពលោករបស់អង្គការសហប្រជាជាតិ
Benjamin Scholz benjamin.scholz@wfp.org, ឡុង យ៉ាវ yav.long@wfp.org , ជឿ ច័ន្ទវិបុល chanvibol.choeur@wfp.org,
ហួយ វណ្ណារ៉េត vannareth.huoy@wfp.org, Akshaya Devasia akshaya.devasia@wfp.org
គេហទំព័រ៖ https://www.wfp.org/countries/cambodia

# បុព្វកថា

**ជម្លោះអ៊ុយក្រែនកំពុងបន្ត និងការដាក់ទណ្ឌកម្មលើរុស្ស៊ី** ធ្វើឱ្យប៉ះពាល់ខ្លាំងដល់ទីផ្សារថាមពល និងស្បៀងអាហារ ដោយសារប្រទេសទាំងពីរជាអ្នកនាំចេញគ្រាប់ធញ្ញជាតិសំខាន់ (ជាពិសេសស្រូវសាឡី និងស្រូវបាឡេ) ជីកសិកម្ម (ដូចជាប៉ូតាស្យូមអាសូត ផូស្វ័រ) ប្រេងឆៅ និងឧស្ម័នធម្មជាតិដ៏ធំរបស់ពិភពលោក។ ធាតុអាកាសអំណោយផល និងការឆ្លើយតបផ្នែកផ្គត់ផ្គង់ដ៏រឹងមាំបានកាត់បន្ថយការកើនឡើងតម្លៃក្នុងឆ្នាំ២០២៣ ប៉ុន្តែការផ្គត់ផ្គង់ដ៏តឹងតែងបង្ហាញពីភាពប្រែប្រួលកាន់តែខ្លាំងជាពិសេសកំឡុងពេលដែលមិនអាចទាយទុកជាមុនបាន ដូចជាពេលវេលាដាំដុះនៅអឌ្ឍគោលខាងជើង។

**ក្នុងខែមេសា ឆ្នាំ២០២៣ សន្ទស្សន៍តម្លៃស្បៀងអាហារសកលរបស់ FAO បានកើនឡើងបន្តិចធៀបនឹងខែមុន (+0,៦%)** ដោយសារសន្ទស្សន៍តម្លៃស្ករសកលកើនឡើងខ្លាំង ប៉ុន្តែវានៅតែទាបជាងខែដូចគ្នាកាលពីឆ្នាំមុន ១៩,៧%។

**ក្នុងខែមេសា ឆ្នាំ២០២៣ IMF បានព្យាករកំណើនសេដ្ឋកិច្ចសកលថាកើន ២,៨% ក្នុងឆ្នាំ២០២៣ ថយពី ៣,៤% ក្នុងឆ្នាំ២០២២។** អតិផរណាសកលដែលបានព្យាកររំពឹងថានឹងថយចុះពី ៨,៧% ក្នុងឆ្នាំ២០២២ មក ៧,0% ក្នុងឆ្នាំ២០២៣ ដោយសារតែការធ្លាក់ចុះតម្លៃទំនិញ មុនពេលបន្តធ្លាក់ដល់ ៤,៩%ក្នុងឆ្នាំ២០២៤ ។

**លទ្ធភាពទទួលបានជីកសិកម្មមានភាពប្រសើរឡើងវិញ ក្នុងឆ្នាំ២០២៣** ដោយសារតែតម្លៃជីបានថយចុះ ៣៧% ចាប់ពីពេលដែលឡើងខ្ពស់បំផុតនៅដើមឆ្នាំ២០២២ - តែនៅតែខ្ពស់ជាងមធ្យមភាគច្រើនឆ្នាំ។ ដូចគ្នាដែរ តម្លៃផលិតកម្មកសិកម្មសកលរំពឹងទុកថានឹងថយចុះ ៧,0% ក្នុងឆ្នាំ២០២៣ ប៉ុន្តែវានៅតែខ្ពស់ជាងពីមុន។ បើទោះជាតម្លៃទាបនៃធាតុចូលកសិកម្មធ្វើឲ្យផលិតកម្មស្បៀងអាហារមានភាពប្រសើរឡើង ប៉ុន្តែភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុ និងភាពមិនច្បាស់លាស់នៃសង្គ្រាមរុស្ស៊ី និងអ៊ុយក្រែននៅតែបន្តធ្វើឱ្យមានហានិភ័យនៃវិបត្តិតម្លៃស្បៀងអាហារសកល។

**វិបត្តិស្បៀងអាហារពិភពលោក ត្រូវបានធ្វើឱ្យកាន់តែធ្ងន់ធ្ងរមួយផ្នែក ដោយការរឹតបន្តឹងពាណិជ្ជកម្មស្បៀងអាហារ** ដែលដាក់ដោយប្រទេសមួយចំនួនដើម្បីបង្កើនការផ្គត់ផ្គង់ក្នុងស្រុក និងកាត់បន្ថយតម្លៃ។ គិតត្រឹមថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ប្រទេសចំនួន ២២ បានជំរុញឱ្យមានការហាមឃាត់ការនាំចេញអាហារ ចំនួន ២៩ ហើយប្រទេសចំនួន ១០ បានអនុវត្តវិធានការកំណត់ការនាំចេញចំនួន ១៤។

**បញ្ហានេះមិនបានកើតឡើងដាច់ដោយឡែកនោះទេ។** កូវីដ-១៩ បានប៉ះពាល់ជាអវិជ្ជមានដល់ប្រាក់ចំណូល និងតម្រូវការគ្រួសារ ជាហេតុធ្វើឱ្យមានឧបសគ្គដល់ខ្សែច្រវ៉ាក់ផ្គត់ផ្គង់សកល កើនឡើងអតិផរណា និងបំណុលក្នុងប្រទេសជាច្រើន - ធ្វើឱ្យរំខានដល់ការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩។ ភ័ស្តុតាងចង្អុលបង្ហាញពីស្ថានភាពសន្តិសុខស្បៀង ដែលមិនមានស្ថិតស្ថេរក្នុងចំណោមគ្រួសារកម្ពុជា ជាពិសេសអ្នកដែលងាយរងគ្រោះបំផុត និងអ្នករស់នៅក្នុងតំបន់ងាយរងគ្រោះដោយទឹកជំនន់។

**ដើម្បីស្វែងយល់ពីឥទ្ធិពលនៃបញ្ហាទាំងនេះ លើភាពមានស្បៀង និងលទ្ធភាពទទួលបានស្បៀង នៅតាមផ្សារនានាក្នុងប្រទេសកម្ពុជា** កម្មវិធីស្បៀងអាហារពិភពលោក (WFP) សហការជាមួយការិយាល័យទីផ្សារកសិកម្ម (AMO) នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (MAFF) តាមដានតម្លៃលក់រាយ និងលក់ដុំ របស់ស្បៀងអាហារសំខាន់ៗ នៅក្នុងផ្សារចំនួន៥៦ ទាំងនៅទីប្រជុំជន និងជនបទទូទាំងប្រទេស (សូមមើលផ្នែកវិធីសាស្រ្ត)។ ប្រធានផ្សារក៏ត្រូវបានសម្ភាសន៍ផងដែរ ដើម្បីវាយតម្លៃពីដំណើរការរបស់ទីផ្សារ ទាំងបញ្ហាផ្គត់ផ្គង់ស្បៀង និងតម្រូវការស្បៀង។ ជាមធ្យម ប្រធានផ្សារ និងអាជីវករចំនួន ១.000 នាក់ ត្រូវបានសម្ភាសន៍ជារៀងរាល់ពីរសប្តាហ៍។ លើសពីនេះទៀត តម្លៃប្រេងសាំង និងប្រេងម៉ាស៊ូត និងប្រាក់ឈ្នួលពលកម្មសម្រាប់វិស័យកសិកម្ម និងសំណង់ក៏ត្រូវបានតាមដានជាទៀងទាត់ផងដែរ។

# មាតិកា


១. **របកគំហើញសំខាន់ៗ** ៣

២. **លទ្ធផល**

ការដំណើរការរបស់ផ្សារ៖ ទិដ្ឋភាពទូទៅ ៤

ការទៅផ្សារ៖ទិន្នាការអតិថិជន ៥

ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៦

ថ្នាក់ក្រោមជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ៧

ថ្នាក់ជាតិ៖ ប្រាក់ឈ្នួលពលកម្ម និងកម្លាំងទិញស្បៀងអាហារ ៨

ថ្នាក់ជាតិ៖ និន្នាការតម្លៃអង្ករចម្រុះ ស៊ុតទា និងត្រកួន ៩

ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា ១០

ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន ១១

ការតាមដានរដូវកាល៖ របាយទឹកភ្លៀង ១២

ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ ១៣

៣. **បរិបទ**

ពាណិជ្ជកម្ម ១៤

ការឆ្លើយតបផ្នែកនយោបាយ ១៥

៤. **វិធីសាស្រ្ត និងទីតាំងផ្សារ** ១៦

៥. **ឧបសម្ព័ន្ធទី១**

បម្រែបម្រួលថ្លៃលក់រាយ ១៧

៦. **ឧបសម្ព័ន្ធទី២**

បម្រែបម្រួលថ្លៃលក់ដុំ ១៨

៧. **ឧបសម្ព័ន្ធទី៣**

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ១៩

## កត្តាបរិស្ថានដែលមានឥទ្ធិពលលើតម្លៃ

**កំណើនសេដ្ឋកិច្ច**

២០២២ **៥,២%**

២០២៣ **៥,៥%**

**អតិផរណា**

CPI កុម្ភៈ ២០២៣ **១៩៩,៧**

CPI មីនា ២០២៣ **២០០,០**

*ធនាគារពិភពលោក បានព្យាករកំណើនសេដ្ឋកិច្ចរបស់កម្ពុជាថានឹងកើន [៥,៥% ក្នុងឆ្នាំ២០២៣]។ ក្នុងខែមីនា ឆ្នាំ២០២៣ សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់រួម* (CPI) បានកើនឡើង ០,១% ធៀបនឹងខែមុន និង ០,៨% ធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន។ គ្រួសារកម្ពុជាចំណាយស្ទើរតែពាក់កណ្ដាល (៤៨,៧%) នៃប្រាក់ចំណូលរបស់ខ្លួនលើស្បៀងអាហារ។ គ្រួសារក្នុងក្រុមចំណាយទាបបំផុតបានចំណាយ រហូតដល់ ៥៦% (CSES ២០១៩/២០)។*

**CPI ក្នុងខែមេសា ឆ្នាំ២០២៣ មិនទាន់មាននៅឡើយទេ កំឡុងពេលរៀបចំរបាយការណ៍។*




*ក្នុងខែមេសា ឆ្នាំ២០២៣ **សន្ទស្សន៍តម្លៃស្បៀងអាហារសកលរបស់ FAO(FFPI)បានកើនឡើង** ០,៨ (+០,៦% MoM និង -១៩,៧% YoY)។ **សន្ទស្សន៍តម្លៃស្បៀងអាហារកម្ពុជា (FPI)** ក្នុងខែមីនា ជាផ្នែកមួយនៃ CPI របស់កម្ពុជា បានកើនឡើង ០,៤% MoM និង ២,៤% YoY (ទិន្នន័យចុងក្រោយមិនទាន់មាននៅឡើយ) ។*




*[តម្លៃប្រេងឥន្ធនៈនៅកម្ពុជា] **ក្នុងខែមេសា ឆ្នាំ២០២៣ បានប្រែប្រួលតិចតួចបើធៀបនឹងខែមុន (MoM) ប៉ុន្តែបានថយចុះខ្លាំងបើធៀបនឹងខែដដែលកាលពីឆ្នាំមុន (YoY) (MOC, ២០២៣)**។ តម្លៃលក់រាយប្រេងសាំងធម្មតា **បានកើនឡើង** ២,៧% MoM តែថយចុះ ១៥,២% YoY។ តម្លៃប្រេងម៉ាស៊ូត បានធ្លាក់ចុះ ១,៦% MoM និង ២២,៦% YoY។ និន្នាការថយចុះនៃតម្លៃប្រេងឥន្ធនៈប្រហែលជាអាចធ្វើឱ្យផលិតកម្ម និងតម្លៃស្បៀងមានភាពប្រសើរឡើង។*

# សង្ខេបរបកគំហើញសំខាន់ៗ

ក្នុងខែមេសា ឆ្នាំ២០២៣ កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) បានកើនឡើងបន្តិច ០,៦% ដល់តម្លៃ ២៥,៦ ដុល្លារ។ ប៉ុន្តែវានៅតែមានតម្លៃទាបជាងខែមេសាកាលពីឆ្នាំមុន ២,៨% នៅពេលដែលតម្លៃស្បៀងអាហារបានកើនឡើងខ្ពស់ជាបន្តបន្ទាប់ដោយសារតែការផ្ទុះឡើងនៃសង្គ្រាមអ៊ុយក្រែន (ផលប៉ះពាល់ដើមគ្រា)។ ស្របតាមលំនាំធម្មតា BFB នៅទីប្រជុំជន (២៦,២ ដុល្លារ) មានតម្លៃខ្ពស់ជាង BFB នៅជនបទ (២៤,៦ ដុល្លារ)។

ស្បៀងអាហារភាគច្រើននៅក្នុងកញ្ចប់មានតម្លៃថេរ ដោយមានបម្រែបម្រួលតិចតួចប៉ុណ្ណោះ (តិចជាង ៥,០% MoM)។ ប៉ុន្តែ តម្លៃស្បៀងអាហារមួយចំនួនដូចជា ស្រីផ្ទក់ (+១១,១%) និងជំឡូងជ្វា (+៣១,៣%)។ ស្បៀងអាហារភាគច្រើនផ្សេងទៀតមានតម្លៃទាបជាងខែដូចគ្នាកាលពីឆ្នាំមុនដោយសារផលប៉ះពាល់ដើមគ្រា។

ដំណើរការរបស់ផ្សារបានធ្លាក់ចុះនៅសប្តាហ៍ទី៣ ខែមេសា ដល់ចំនុចទាបជាងគេបំផុតក្នុងឆ្នាំ២០២៣។ ការធ្លាក់ចុះនេះដោយសារការកើនឡើងនៃបំរែបំរួល និងភាពមិនអាចព្យាករបាននៃតម្លៃទំនិញចាំបាច់ ដោយសារតែការកើនឡើងនូវតម្លៃប្រេងសាំងនៅ២០ថ្ងៃចុងក្រោយខែមេសា (+៤,១% ខ្ពស់ជាងថ្ងៃ១០ដំបូង)។

ផលិតកម្មស្រូវរដូវប្រាំង ដែលបានប្រមូលផលរួចរាល់ ៧៥% រំពឹងទុកថានឹងទទួលបានប្រមាណ ២,៥ លានតោន ថយចុះពី ២,៩ លានតោន ក្នុងឆ្នាំ២០២២។ បន្ថែមលើនេះ បាតុភូតអែលនីញ៉ូរំពឹងទុកថានឹងមានឥទ្ធិពលខ្លាំងនៅក្នុងតំបន់ កំឡុងពេលរដូវវស្សាឆ្នាំ២០២៣ ជាហេតុធ្វើ ឱ្យមានភ្លៀងធ្លាក់យឺត និងមានបរិមាណទឹកភ្លៀងទាបជាងមធ្យមភាគច្រើនឆ្នាំ។ ជាលទ្ធផល ទិន្នផលកសិកម្មអាចនឹងទទួលផលប៉ះពាល់ ហើយក៏អាចប៉ះពាល់ដល់តម្លៃស្បៀងអាហារផងដែរ។

# ការដំណើរការរបស់ផ្សារ

សន្ទស្សន៍ដំណើរការផ្សារ (MFI)[1] វាស់វែងពីដំណើរការរបស់ផ្សារដែលបានតាមដាន ដោយផ្អែកលើសមាសធាតុសំខាន់ៗ៖ ភាពចម្រុះនៃទំនិញចាំបាច់ ភាពអាចរកបានជាក់ស្តែងនៃទំនិញក្នុងបរិមាណគ្រប់គ្រាន់ តម្លៃដែលអាចព្យាករបាននិងមានស្ថេរភាព និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់។ ពិន្ទុ MFI នៅចន្លោះពី០ ដល់១០ ដែលពិន្ទុកាន់តែខ្ពស់បង្ហាញពីដំណើរការកាន់តែល្អ។

ដំណើរការរបស់ផ្សារ[2]មានភាពប្រសើរឡើងបន្តិចនៅក្នុងសប្តាហ៍ទី១ ខែមេសា ឆ្នាំ២០២៣ ប៉ុន្តែវាបានថយចុះនៅសប្តាហ៍ទី៣ ដល់ពិន្ទុទាបបំផុតប្រចាំឆ្នាំ។ នេះដោយសារតែការប្រែប្រួល និងភាពមិនអាចព្យាករបាននៃតម្លៃទំនិញសំខាន់ៗនៅក្នុងផ្សារ ដោយសារតែតម្លៃប្រេងសាំងបានកើនឡើងគួរឱ្យកត់សម្គាល់នៅពីរសប្តាហ៍ចុងក្រោយ។ មិនមានប្រធានផ្សារ និងអ្នកលក់ដែលបានសម្ភាសន៍បានរាយការណ៍ពីការកើនឡើងតម្លៃផ្គត់ផ្គង់នៅក្នុងខែមេសា ឆ្នាំ២០២៣ នេះទេ បើធៀបនឹង ១០,៨% ក្នុងខែមុន។




*[1]សមាសធាតុទាំងបួន ដូចជា ភាពចម្រុះនៃទំនិញ ភាពមានស្បៀង តម្លៃស្បៀង និងភាពធន់នៃខ្សែច្រវាក់ផ្គត់ផ្គង់នៅក្នុងសន្ទស្សន៍ដំណើរការផ្សារសង្ខេប គឺជាសន្ទស្សន៍ ដែលមានពីលេខ០ ដល់លេខ១០ ហើយតម្លៃកាន់តែខ្ពស់បង្ហាញថា ផ្សារមានដំណើរការកាន់តែល្អកំឡុងពេលតាមដាន។ សន្ទស្សន៍ដំណើរការផ្សារជារួមគឺជាការបញ្ចូលគ្នានៃសមាសធាតុទាំងបួន។ <u>លម្អិតពីវិធីសាស្ត្ររបស់សន្ទស្សន៍ដំណើរការផ្សារ</u>។ ចាប់ពីពាក់កណ្តាលខែកញ្ញា ឆ្នាំ២០២២មក ព័ត៌មានស្តីពីទំនិញមិនមែនស្បៀងអាហារក៏ត្រូវបានបញ្ចូលទៅក្នុងការវិភាគនេះដែរ។*

*[2]ការគណនា MFI និងសមាសធាតុសំខាន់ៗត្រូវបានកែសម្រួលដើម្បីបង្ហាញព័ត៌មានកាន់តែសុក្រិត។*

# ការនៅផ្សារ៖ ទិន្នាការអតិថិជន

ប្រធានផ្សារ និងអ្នកលក់តាមបណ្តាផ្សារចំនួន ៥៦ កន្លែង ដែលបានតាមដានតម្លៃនៅទូទាំងប្រទេស ក៏ត្រូវបានសម្ភាសន៍ស្តីពីភាពងាយស្រួលក្នុងការធ្វើដំណើរទៅផ្សារ និងចំនួនអតិថិជនទៅផ្សាររបស់ពួកគាត់នៅសប្តាហ៍ទី១ និងសប្តាហ៍ទី៣ នៃខែនីមួយៗ។

ចំនួនអតិថិជនបានទៅផ្សារបានកើនឡើងបង្គួរក្នុងសប្តាហ៍ទី១ ខែមេសា ឆ្នាំ២០២៣ មុនពេលដែលបានធ្លាក់ចុះបន្តិចវិញក្នុងសប្តាហ៍ទី៣។ នេះអាចបណ្តាលមកពីការពិតដែលថា មានមនុស្សច្រើនទៅផ្សារដើម្បីទិញស្បៀងអាហារ និងទំនិញផ្សេងៗដើម្បីរៀបចំពិធីបុណ្យចូលឆ្នាំខ្មែរ ដែលប្រារព្ធឡើងពីថ្ងៃទី១៤ ដល់ថ្ងៃទី១៦ ខែមេសា ឆ្នាំ២០២៣ ប៉ុន្តែចំនួនអ្នកទៅផ្សារបានថយចុះបន្ទាប់ពីចប់ពិធីបុណ្យ។




**បម្រែបម្រួល[1]នៃចំនួនអតិថិជនមកផ្សារ**

*[1]តម្លៃលេខបង្ហាញពីបម្រែបម្រួលនៃចំនួនអតិថិជនត្រូវបានគណនាដោយប្រើសន្ទស្សន៍កំណើន/តំហាយ (diffusion index) ដើម្បីតាមដានពីការប្រែប្រួលអតិថិជនមកផ្សារក្នុងសេរីពេលវេលា។*

# ថ្នាក់ជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP ត្រូវបានគណនាដើម្បីជាជំនួយក្នុងការបកស្រាយផលប៉ះពាល់នៃការប្រែប្រួលតម្លៃស្បៀងប្រចាំខែលើតម្លៃរបបអាហារប្រកបដោយអាហារូបត្ថម្ភដែលបានទទួលទាននៅកម្ពុជា។

ក្នុងខែមេសា ឆ្នាំ២០២៣ តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានបានកើនឡើងបន្តិច ០,៦% ធៀបនឹងខែមុន (MoM) ដល់តម្លៃ ១០៩.៨៨៧ រៀល/ម្នាក់/ខែ (ប្រហែល ២៥,៦ ដុល្លារ) ប៉ុន្តែទាបជាងខែដដែលកាលពីឆ្នាំមុន ២,៨% (YoY)។ ស្របតាមលំនាំធម្មតា កញ្ចប់ស្បៀងអាហារមូលដ្ឋាននៅជនបទ (២៤,៦ ដុល្លារ) មានតម្លៃទាបជាងនៅទីប្រជុំជន (២៦,២ ដុល្លារ)។




## កញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របបអាហារប្រចាំថ្ងៃសម្រាប់មនុស្សម្នាក់



*កញ្ចប់ស្បៀងអាហារមូលដ្ឋានមានបញ្ចូលនូវស្បៀងអាហារសំខាន់ៗ រួមមាន អង្ករចម្រុះ ត្រីផ្ទក់ សាច់ជ្រូក ស៊ុតទា ប្រេងឆា ដំឡូងជ្វា និងត្រកួន ដែលផ្តល់ថាមពលអប្បបរមាចាំបាច់ចំនួន ១.៩៣៧ កាឡូរី សម្រាប់មនុស្សម្នាក់ក្នុងមួយថ្ងៃ។ កញ្ចប់ស្បៀងអាហារមូលដ្ឋានត្រូវបានវិភាគដោយផ្អែកលើកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា របស់ WFP។ សូមមើលឧបសម្ព័ន្ធទី៣ សម្រាប់ព័ត៌មានពីវិធីសាស្ត្រ។*

# ថ្នាក់ក្រោមជាតិ៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន (BFB) របស់ WFP មានការប្រែប្រួលទៅតាមខេត្ត និងផ្សារ។ តម្លៃកញ្ចប់ស្បៀងអាហារខ្ពស់ជាងគេស្ថិតនៅផ្សារតាខ្មៅ ក្នុងខេត្តកណ្តាល គឺ ១១៤.២០០ រៀល/ម្នាក់/ខែ (ប្រហែល ២៧,៨ ដុល្លារ) ដែលខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ ៨,៩%។ តម្លៃ BFB ទាបជាងគេស្ថិតក្នុងផ្សារស្ទោយ ក្នុងខេត្តកំពង់ធំ គឺ ៩២.៩០០ រៀល/ម្នាក់/ខែ (ប្រហែល ២២,៧ ដុល្លារ) ដែលទាបជាងតម្លៃមធ្យមថ្នាក់ជាតិ១១,៤%។ ផែនទីខាងក្រោមបង្ហាញពីតម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន និងបម្រែបម្រួលធៀបនឹងតម្លៃកញ្ចប់មធ្យមថ្នាក់ជាតិ។

តម្លៃកញ្ចប់ស្បៀងអាហារដែលមានបម្រែបម្រួលខ្ពស់ជាងតម្លៃមធ្យមថ្នាក់ជាតិ (៥% និងខ្ពស់ជាងឡើងទៅ) គឺភាគច្រើនមាននៅផ្សារនៅទីប្រជុំជន ជាងនៅក្នុងផ្សារនៅជនបទ។

### តម្លៃកញ្ចប់ស្បៀងអាហារមូលដ្ឋានតាមផ្សារ ឬខេត្ត ធៀបនឹងតម្លៃកញ្ចប់ជាមធ្យមថ្នាក់ជាតិ (ខែមេសា ឆ្នាំ២០២៣)




| បម្រែបម្រួលពីតម្លៃមធ្យមថ្នាក់ជាតិ | ភាគរយនៃផ្សារនៅ ជនបទ | ភាគរយនៃផ្សារនៅ ទីប្រជុំជន |
|---|---|---|
| ≥ ១០% ខ្ពស់ជាង | ០% | ០% |
| ៥% ទៅ ១០% ខ្ពស់ជាង | ១៧% | ៨៣% |
| < ៥% ខ្ពស់ជាង | ៥០% | ៥០% |
| < ៥% ទាបជាង | ៤០% | ៦០% |
| ៥% ទៅ ១០% ទាបជាង | ៥៧% | ៤៣% |
| ≥ ១០% ទាបជាង | ៦៧% | ៣៣% |

# ថ្នាក់ជាតិ៖ ប្រាក់ឈ្នួលពលកម្ម និងកម្លាំងទិញស្បៀងអាហារ

ប្រាក់ឈ្នួលពលកម្មសម្រាប់កម្មករក្នុងវិស័យកសិកម្ម និងសំណង់ត្រូវបានប្រមូលជារៀងរាល់ខែនៅទូទាំងប្រទេសដោយ AMO។ ក្នុងខែមេសា ឆ្នាំ២០២៣ តម្លៃមធ្យមថ្នាក់ជាតិប្រាក់ឈ្នួលពលកម្ម[1]បានកើនឡើងបន្តិចបើធៀបនឹងខែមុន (+0,៧% MoM) ដល់ ៣៧.២៦១ រៀលក្នុងមួយថ្ងៃ (ប្រហែល ៩,១ ដុល្លារ)។ តម្លៃនេះខ្ពស់ជាង (+១៤,៧%) តម្លៃកាលពីខែមេសា ឆ្នាំ២០២២ គួរឱ្យកត់សម្គាល់។

កម្លាំងទិញស្បៀងអាហារ (ToT) ត្រូវបានប្រើសម្រាប់វាយតម្លៃពីកម្លាំងទិញស្បៀងអាហាររបស់គ្រួសារ ហើយត្រូវបានវាស់វែងដោយប្រើផលធៀបរវាងអត្រាប្រាក់ឈ្នួលកម្មករគ្មានជំនាញ និងតម្លៃមធ្យមកញ្ចប់ស្បៀងអាហារមូលដ្ឋាន។ វាបង្ហាញពីបរិមាណស្បៀងអាហារ ដែលកម្មករគ្មានជំនាញអាចទិញដោយប្រើប្រាស់ប្រាក់ឈ្នួលក្នុងមួយថ្ងៃរបស់គាត់។ ក្នុងខែមេសា ឆ្នាំ២០២៣ ToT បានកើនឡើងបន្តិចគឺ ០,៩% បើធៀបនឹងខែមុន ដោយសារការកើនឡើងនៃប្រាក់ឈ្នួលពលកម្មខ្ពស់ជាងការកើនឡើងតម្លៃមធ្យមកញ្ចប់ស្បៀងអាហារមូលដ្ឋាន។ តួលេខនេះបានកើនឡើងគួរឱ្យកត់សម្គាល់គឺ ១៨,០% បើធៀបនឹងខែដូចគ្នាកាលពីឆ្នាំមុន ដែលបង្ហាញថាកម្លាំងទិញស្បៀងអាហាររបស់ក្រុមប្រជាជនទាំងនោះកាន់តែមានភាពប្រសើរឡើង។

**ប្រាក់ឈ្នួលពលកម្ម**
(ខែមេសា ឆ្នាំ២០២៣)




**កម្លាំងទិញស្បៀងអាហារ**
(ខែមេសា ឆ្នាំ២០២៣)




[1] *នេះជាប្រាក់ឈ្នួលពលកម្ម ដែលមិនទាន់បានកែសម្រួលជាមួយអតិផរណា*

# **ថ្នាក់ជាតិ៖** និន្នាការតម្លៃអង្ករ ស៊ុតទា និងត្រកួន

កំឡុងខែមេសា ឆ្នាំ២០២៣ តម្លៃមធ្យមលក់រាយត្រកួនបន្តថយចុះ ៥,៧%។ ផ្ទុយមកវិញ តម្លៃមធ្យមលក់រាយអង្ករ និងស៊ុតទាបានកើនឡើងបន្តិច គឺ ០,៧% ធៀបនឹងខែមុន (MoM)។ តម្លៃត្រកួនបានថយចុះគួរឱ្យកត់សម្គាល់ជាងឆ្នាំមុន គឺ ៧,៩% ហើយតម្លៃស៊ុតទាបានថយចុះគួរឱ្យកត់សម្គាល់ជាងឆ្នាំមុន ៥,៥% ខណៈតម្លៃអង្ករចម្រុះបានកើនឡើងបន្តិច ៣,៧% YoY។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃនៃស្បៀងអាហារផ្សេងៗទៀត។*




[1]ត្រកួនគឺបន្លែដែលត្រូវបានទទួលទានជាទូទៅនៅប្រទេសកម្ពុជា ហើយនិន្នាការតម្លៃរបស់វាមិនបង្ហាញពីការឡើងចុះតម្លៃបន្លែផ្សេងទៀតនៅក្នុងឧបសម្ព័ន្ធនោះទេ។
[2]តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ

# ថ្នាក់ជាតិ៖ និន្នាការតម្លៃត្រីផ្ទក់ សាច់ជ្រូក និងប្រេងឆា

ក្នុងខែមេសា ឆ្នាំ២០២៣ តម្លៃមធ្យមលក់រាយប្រេងឆាថយចុះ ២,២% ខណៈតម្លៃមធ្យមលក់រាយសាច់ជ្រូកបានកើនឡើង ២,៨% ហើយត្រីផ្ទក់បានកើនឡើង ៣,៥% ធៀបនឹងខែមុន។ ធៀបនឹងខែដូចគ្នាកាលឆ្នាំមុន តម្លៃប្រេងឆាថយចុះ ១៩,៤% ហើយតម្លៃសាច់ជ្រូកថយចុះ ២០,១% ចំណែកត្រីផ្ទក់នៅតែមានតម្លៃខ្ពស់ជាងខែដូចគ្នាកាលពីឆ្នាំមុន (១១,១%)។

*សូមមើលឧបសម្ព័ន្ធទី១ និងទី២ សម្រាប់តម្លៃស្បៀងអាហារផ្សេងៗទៀត។*




[1]តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ

# ថ្នាក់ក្រោមជាតិ៖ ភាពខុសគ្នា និងបម្រែបម្រួលនៃតម្លៃនៅជនបទ និងទីប្រជុំជន

នៅក្នុងខែមេសា ឆ្នាំ២០២៣ ស្បៀងអាហារសំខាន់ៗ ដែលបានកំពុងតាមដាន នៅទីប្រជុំជនមានតម្លៃមធ្យមលក់រាយខ្ពស់ជាងនៅជនបទ លើកលែងអង្ករចម្រុះ និងប្រេងឆា (តារាង១)។

ប្រៀបធៀបនឹងខែមុន តម្លៃមធ្យមលក់រាយស្បៀងអាហារនៅក្នុងផ្សារកំពុងតាមដាន មានបម្រែបម្រួលតិចតួច (<៥,០%) ហើយភាគច្រើនមានទិសដៅបម្រែបម្រួលដូចគ្នា (លើកលែងតែត្រកួន និងជំឡូងជ្វា) ទាំងនៅទីប្រជុំជន និងទីជនបទ បើធៀបនឹងខែមុន។ តម្លៃត្រកួនបានថយចុះទាំងនៅទីប្រជុំជន និងទីជនបទ ដោយថយចុះច្រើននៅទីប្រជុំជនគឺ ៨,៧% និង ៣,៦% នៅជនបទ។ តម្លៃជំឡូងជ្វាបានថយចុះគួរឱ្យកត់សម្គាល់ ១៩,០% (MoM) នៅជនបទ ប៉ុន្តែបានកើនឡើងបង្គួរ ៧,៧% (MoM) នៅទីប្រជុំជន។

**តារាង១៖ តម្លៃលក់រាយ (រៀល) នៅជនបទ និងទីប្រជុំជន**

| | ទីប្រជុំជន | ជនបទ |
|---|---|---|
| អង្ករ (គក) | ២.១៣៤ | ២.១៤៩ |
| ត្រីផ្ទក់ (រស់) (គក) | ១១.៥៥០ | ១០.៦៦៣ |
| សាច់ជ្រូក (គក) | ១៦.៣៩៣ | ១៦.២៧២ |
| ស៊ុតទា (១០គ្រាប់) | ៥.៣៤៤ | ៥.៣២១ |
| ប្រេងឆា (៥លីត្រ) | ២៧.៦៥៩ | ២៨.៣៨៩ |
| ត្រកួន (គក) | ២.៩២៦ | ២.៤៧៧ |
| ជំឡូងជ្វាពណ៌លឿង | ៣.៥៧១ | ២.៣៥០ |

## បម្រែបម្រួលប្រចាំខែ (%) នៃតម្លៃលក់រាយស្បៀងអាហារសំខាន់ៗ

### ខែមីនា ឆ្នាំ២០២៣ និង ខែមេសា ឆ្នាំ២០២៣




*[1] ទិន្នន័យនេះទទួលបានពីផ្សារចំនួន៥៦។ សូមមើលផ្នែកវិធីសាស្ត្រសម្រាប់ព័ត៌មានលម្អិត។*
*[2] តម្លៃស្បៀងអាហារត្រូវបានប្រមូលតាមទូរស័ព្ទ*

# ការតាមដានរដូវកាល៖ របាយទឹកភ្លៀង

ក្នុងខែមេសា ឆ្នាំ២០២៣ កម្ពស់ទឹកភ្លៀងជាមធ្យមថ្នាក់ជាតិសរុបមានកម្រិតទាបជាងមធ្យមភាគច្រើនឆ្នាំបង្គួរ (ក្រាហ្វិកខាងក្រោមខាងឆ្វេង)។ នៅទូទាំងប្រទេសមានស្ថានភាពភ្លៀងធ្លាក់ទាបជាងធម្មតាបង្គួរ។ ខេត្តបន្ទាយមានជ័យស្ថិតនៅភាគពាយ័ព្យប្រទេសមានស្ថានភាពស្ងួតជាងគេ ខណៈបណ្តាខេត្តស្ថិតនៅតាមបណ្តោយដងទន្លេមេគង្គមិនសូវស្ងួតខ្លាំងនោះទេ (ផែនទីខាងក្រោមខាងស្តាំ)។

<u>ការព្យាករ El Niño, La Niña និង Southern Oscillation (ENSO)</u> បានបង្ហាញថាបាតុភូតអែលនីញ៉ូទំនងជាកើតមានចន្លោះខែឧសភាដល់ខែកក្កដា ជាហេតុធ្វើឱ្យរដូវវស្សាចាប់ផ្តើមយឺត និងធ្វើឱ្យមានភ្លៀងធ្លាក់ទាបជាងមធ្យមភាគច្រើនឆ្នាំ។ ការព្យាករតាមរដូវកាលចន្លោះខែឧសភាដល់ខែកក្កដា ឆ្នាំ២០២៣ បានបង្ហាញថា ខេត្តភាគខាងលិច និងខាងត្បូងប្រទេសទំនងជាទទួលបានទឹកភ្លៀងទាបជាងធម្មតា ខណៈខេត្តភាគឦសានប្រទេសរំពឹងទុកថានឹងមានទឹកភ្លៀងចន្លោះពីធម្មតាទៅច្រើនជាងធម្មតា (<u>IRI Columbia University</u> និង <u>ECMWF</u>)។ ផ្អែកតាម<u>សេចក្តីប្រកាសរបស់ក្រសួងធនធានទឹក និងឧតុនិយម</u> នៅថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣ រដូវវស្សាត្រូវបានព្យាករថានឹងចាប់ផ្តើមយឺតក្នុងសប្តាហ៍ទី២ខែឧសភា ហើយរំពឹងទុកថានឹងទទួលបានបរិមាណទឹកភ្លៀងពីតិចទៅមធ្យម ដែលទាបជាងមធ្យមភាគច្រើនឆ្នាំប្រមាណ ២០% ទៅ៣០% កំឡុងពេលរដូវវស្សាខាងមុខនេះ។ លើសពីនេះទៀត កូនរដូវប្រាំងទំនងជាកើតឡើង និងអូសបន្លាយចម្លោះខែកក្កដាដល់ខែសីហា។

## បរិមាណទឹកភ្លៀងមធ្យមថ្នាក់ជាតិ (ខែមេសា ឆ្នាំ២០២៣) និងប្រតិទិនដាំដុះតាមរដូវកាល




| | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| ស្រូវរដូវប្រាំង | ដាំដុះ | ដាំដុះ | ប្រមូលផល | ប្រមូលផល | | | | | | | រៀបចំដី និងសាបព្រោះ | រៀបចំដី និងសាបព្រោះ |
| ស្រូវរដូវវស្សា | ប្រមូលផល | ប្រមូលផល | | | រៀបចំដី និងសាបព្រោះ | រៀបចំដី និងសាបព្រោះ | ស្ទូង / ដាំដុះ | ស្ទូង / ដាំដុះ | ស្ទូង / ដាំដុះ | ស្ទូង / ដាំដុះ | ប្រមូលផល | ប្រមូលផល |

*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

## ភាពមិនប្រក្រតីនៃទឹកភ្លៀង ក្នុងខែមេសា ឆ្នាំ២០២៣




*ប្រភព៖ ទិន្នន័យទឹកភ្លៀងពី CHIRPS និងវិភាគដោយ WFP*

# ការតាមដានរដូវកាល៖ ស្ថានភាពរុក្ខជាតិ និងដំណាំ

ភ្លៀងធ្លាក់តិចជាងធម្មតានៅក្នុងខែមេសា ឆ្នាំ២០២៣ បានធ្វើឱ្យសុខភាពរុក្ខជាតិថយចុះនៅទូទាំងប្រទេស។ ស្ថានភាពរុក្ខជាតិទាបជាងមធ្យមភាគស្ថិតនៅទូទាំងប្រទេសក្នុងខែមេសា ឆ្នាំ២០២៣ (ផែនទីខាងស្ដាំ)។

ការប្រមូលផលស្រូវរដូវប្រាំងជិតបញ្ចប់ស្ទើរតែទាំងស្រុងហើយនៅក្នុងប្រទេសកម្ពុជា។ គិតត្រឹមថ្ងៃទី២២ ខែមីនា ឆ្នាំ២០២៣ ៧៥% នៃផ្ទៃដីបង្កបង្កើនផលសរុបស្រូវរដូវប្រាំង (៦៨១.៨៤៧ ហិកតា) ត្រូវបានប្រមូលផលដោយជោគជ័យ ជាមួយនឹងទិន្នផលជាមធ្យម ៤,៧ តោន ក្នុងមួយហិកតា។ វារំពឹងទុកថានឹងទទួលបានទិន្នផលសរុបចំនួន ២,៥ លានតោន (ដកស្រង់ដោយកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី១៩ ខែមេសា ឆ្នាំ២០២៣)។

**ភាពមិនប្រក្រតីនៃសន្ទស្សន៍ភាពខុសគ្នានៃរុក្ខជាតិ (NDVI)**
**ក្នុងខែមេសា ឆ្នាំ២០២៣**




*ប្រភព៖ NDVI ពី MODIS និងវិភាគដោយ WFP*
*ចំណាំ៖ ការបកស្រាយពីស្ថានភាពរុក្ខជាតិមានកម្រិតសម្រាប់តំបន់គ្របដណ្តប់ដោយពពកឬមិនមានទន្និន័យ*

# ពាណិជ្ជកម្ម

គិតត្រឹមខែមេសា ស្ថិតិសរុបនៃពាណិជ្ជកម្មក្នុងឆ្នាំ២០២៣ នៅតែទាបជាងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ក្នុងរយៈពេលបួនខែដំបូងឆ្នាំ២០២៣ ការនាំចេញផ្លូវការសរុបរបស់កម្ពុជាមានតម្លៃ ៧.២៣៤ លានដុល្លារ ដែលទាបជាងរយៈពេលដដែលកាលពីឆ្នាំមុនប្រមាណ ៤,៩%។ ទិន្នន័យនាំចេញអង្ករបស់កម្ពុជាសម្រាប់ខែមេសា ឆ្នាំ២០២៣ មិនទាន់មាននៅឡើយកំឡុងពេលរាយការណ៍នេះ។ ក្នុងរយៈពេលបីខែដំបូងឆ្នាំ២០២៣ ការនាំចេញអង្ករមានចំនួន ១៧៦.៥៨១ តោន (មានតម្លៃស្មើ ១២៦ លានដុល្លារ) បានថយចុះ ៣,៥% ធៀបនឹងរយៈពេលដដែលកាលពីឆ្នាំមុន ហើយការនាំចេញស្រូវមានចំនួន ១.៥៦០.៥១២ តោន (មានតម្លៃស្មើនឹង ៣៩០,១២ លានដុល្លារ) (ដកស្រង់ដោយកាសែតប្រែសញ្ញូវ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣)។ បន្ថែមលើនេះ គិតត្រឹមខែមីនា ឆ្នាំ២០២៣ កម្ពុជាបាននាំចេញដំឡូងមីស្រស់ចំនួន ១៥៥.២១០ តោន (មានតម្លៃស្មើនឹង ២៨៥ លានដុល្លារ) គឺ ៣០% ខ្ពស់ជាងរយៈពេលដូចគ្នាកាលពីឆ្នាំមុន (ដកស្រង់ដោយកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣))។

ក្នុងរយៈពេលបួនខែដំបូងឆ្នាំ២០២៣ ប្រទេសកម្ពុជាបាននាំចូលជាផ្លូវការសរុបមានតម្លៃ ៧.៩២៦,៩ លានដុល្លារ ក្នុងនោះមានទំនិញជាស្បៀងអាហារចំនួន ៤០២,៤ លានដុល្លារ ដែលរួមមាន៖ ធញ្ញជាតិសរុបចំនួន ២៥,៣ លានដុល្លារ (+១៦,២% ធៀបឆ្នាំមុន) និងអាហារដទៃទៀត (ដូចជា៖ សាច់/សំណល់សាច់/គ្រឿងក្នុងដែលអាចបរិភោគបាន បន្លែដែលអាចបរិភោគបាន ឫស/មើម និងខ្លាញ់សត្វ ប្រេងរុក្ខជាតិ) ចំនួន ៣៧៧,១ លានដុល្លារ (+២,៣%)។ ប្រទេសកម្ពុជាក៏បាននាំចូលជីកសិកម្មចំនួន ៨៣,៣ លានដុល្លារ (+១៣,១% ធៀបឆ្នាំមុន) ក្នុងរយៈពេលដូចគ្នា។

កំពង់ផែស្វយ័តក្រុងព្រះសីហនុរបស់ប្រទេសកម្ពុជានឹងប្រែក្លាយខ្លួនពីកំពង់ផែ ដែលមានសមត្ថភាពទទួលកប៉ាល់កុងតឺន័រតូចៗ ទៅជាកំពង់ផែសមុទ្រ ដែលនឹងអាចផ្ទុកកប៉ាល់កុងតឺន័រធំៗនៅឆ្នាំ ២០២៩ ដែលអាចកាត់បន្ថយការចំណាយលើការដឹកជញ្ជូនទំនិញតាមសមុទ្ររបស់កម្ពុជាយ៉ាងច្រើន ទាក់ទាញអ្នកវិនិយោគកាន់តែច្រើន និងជំរុញឱ្យសេដ្ឋកិច្ចកម្ពុជាកាន់តែកើនឡើង (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី២ ខែឧសភា ឆ្នាំ ២០២៣)។

បន្ទាប់ពីបានប្រកាសពីការបញ្ចប់យ៉ាងសំខាន់នៃការចរចានៅក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី៤០ និងទី៤១ កិច្ចព្រមព្រៀងធ្វើឱ្យប្រសើរឡើងនៃតំបន់ពាណិជ្ជកម្មសេរីអាស៊ាន-អូស្ត្រាលី-នូវែលសេឡង់ (AANZFTA) នឹងត្រូវចុះហត្ថលេខានៅខែសីហា ឆ្នាំ២០២៣ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ២០២៣) ហើយត្រូវបានរំពឹងទុកថានឹងជំរុញសេដ្ឋកិច្ចក្រោយការរាតត្បាតជំងឺ និងធ្វើឱ្យខ្សែច្រវ៉ាក់ផ្គត់ផ្គង់មានភាពធន់។

## សមតុល្យពាណិជ្ជកម្មកម្ពុជា (គិតជាលានដុល្លារ) នៃក្រុមទំនិញសំខាន់ៗ ខែមេសា ឆ្នាំ២០២៣




*ប្រភព៖ អគ្គនាយកដ្ឋានគយនិងរដ្ឋាករ ថ្ងៃទី ១០ ខែឧសភា ឆ្នាំ២០២៣*

# ការឆ្លើយតបផ្នែកនយោបាយ

## គោលនយោបាយឆ្លើយតបលើការគាំពារសង្គម

ផែនការស្តារសេដ្ឋកិច្ចពីការរាតត្បាតកូវីដ-១៩ របស់រដ្ឋាភិបាលមានបញ្ចូលនូវវិធានការគាំពារសង្គមនានា។ ចាប់ពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រដ្ឋាភិបាលបានអនុវត្តកម្មវិធីជំនួយសាច់ប្រាក់ដល់គ្រួសារក្រីក្រ និងងាយរងគ្រោះនៅទូទាំងប្រទេស ដែលប៉ះពាល់ដោយការរាតត្បាតកូវីដ-១៩។ គ្រួសារក្រីក្រប្រមាណ ៧០៤.៩៨០ គ្រួសារ (ប្រមាណ ២,៧៨ លាននាក់) បានទទួលសាច់ប្រាក់ឧបត្ថម្ភ សរុបជាទឹកប្រាក់ចំនួន ១,០២៥,៥៣ លានដុល្លារ គិតចាប់ពីដំណើរការកម្មវិធីដំបូងនៅថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ រហូតដល់ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០២៣។ កម្មវិធីនេះនឹងបន្តក្នុងឆ្នាំ២០២៣។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (MOSVY) បានចុះហត្ថលេខាលើអនុសារណៈយោគយល់គ្នាជាមួយអង្គការចំនួន ១៣១ ក្នុងគោលបំណងផ្តល់ជំនួយដល់កុមារក្រីក្រ ដែលកំពុងជួបប្រទះការលំបាកទាំងការសិក្សា និងស្ថានភាពហិរញ្ញវត្ថុ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី៥ ខែឧសភា ឆ្នាំ២០២៣)។

## គោលនយោបាយឆ្លើយតបផ្នែកសេដ្ឋកិច្ច

"គោលនយោបាយប្រសិទ្ធភាពថាមពលជាតិ ឆ្នាំ២០២២-២០៣០" មានគោលបំណងកាត់បន្ថយការប្រើប្រាស់ថាមពលសរុបនៅក្នុងប្រទេសកម្ពុជាយ៉ាងហោចណាស់ ១៩% ដោយការជំរុញប្រសិទ្ធភាពថាមពល កាត់បន្ថយការពឹងផ្អែកលើការនាំចូលថាមពល និងកាត់បន្ថយតម្រូវការវិនិយោគលើ ហេដ្ឋារចនាសម្ព័ន្ធថាមពលថ្មី ដែលនឹងនាំឱ្យតម្លៃថាមពលអ្នកប្រើប្រាស់ចុងក្រោយថយចុះ (ដកស្រង់ដោយកាសែតខ្មែរថាមស៍ ថ្ងៃទី១ ខែឧសភា ឆ្នាំ២០២៣)។

ព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍ (ស៊ីហ្គេម) លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ក្នុងខែឧសភា-មិថុនា ក៏ដូចជាការបោះឆ្នោតក្នុងខែកក្កដា នឹងមានផលវិជ្ជមានលើការប្រើប្រាស់នៅក្នុងប្រទេស។ ព្រឹត្តិការណ៍ទាំងនេះ ទំនងជាធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចកើនឡើង និងបង្កើតឱកាសសម្រាប់អាជីវកម្ម ដើម្បីបំពេញតម្រូវការរបស់អ្នកទស្សនា និងអ្នកចូលរួម (ដកស្រង់ដោយកាសែតភ្នំពេញប៉ុស្តិ៍ ថ្ងៃទី៤ ខែមេសា ឆ្នាំ២០២៣)។ អាជ្ញាធររាជធានីភ្នំពេញ បានចេញសេចក្តីថ្លែងការណ៍មួយ ទាក់ទងនឹងការរៀបចំរថយន្តក្រុងសម្រាប់ភ្ញៀវជាតិ និងបរទេសទាំងអស់ ដែលចូលរួមក្នុងព្រឹត្តិការកីឡានេះដោយឥតគិតថ្លៃ ចាប់ពីថ្ងៃទី៥ ខែឧសភា ដល់ថ្ងៃទី៩ ខែមិថុនា។

## ការចាក់វ៉ាក់សាំងកូវីដ-១៩

ផ្អែកតាមក្រសួងសុខាភិបាល គិតត្រឹមថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២៣ ពលរដ្ឋអាយុលើសពី៣ឆ្នាំចំនួន ១៥,៣០ លាននាក់ (៥០,៩% ជាស្ត្រី) បានទទួលវ៉ាក់សាំងកូវីដ-១៩ យ៉ាងតិចដូសទី១ សម្រេចតាមផែនការថ្នាក់ជាតិ ១០៤,៩% (៩៥,៥៣% នៃប្រជាជនសរុប)។ អង្គការសុខភាពពិភពលោកបានប្រកាសថា បច្ចុប្បន្នជំងឺកូវីដ-១៩ គឺជាបញ្ហាសុខភាពចាប់លាប់ ដែលលែងចាត់ទុកភាពអាសន្នផ្នែកសុខភាពសាធារណៈ នៃការព្រួយបារម្ភជាអន្តរជាតិ (PHEIC) ទៀតហើយ។ នាយករដ្ឋមន្ត្រីកម្ពុជា នៅថ្ងៃទី១៩ ខែមេសា បានប្រកាសថា មិនចាំបាច់មានការពាក់ម៉ាស់ និងធ្វើតេស្តរហ័សជំងឺកូវីដ-១៩ សម្រាប់ការជួបជុំនានា រួមទាំងការប្រកួតកីឡាស៊ីហ្គេមនាពេលខាងមុខនេះទេ។ ទោះជាយ៉ាងណាក៏ដោយ បុគ្គលម្នាក់ៗអាចជ្រើសរើសពាក់ម៉ាស់ និងធ្វើតេស្តដោយខ្លួនឯង ប្រសិនបើពួកគេមានការព្រួយបារម្ភអំពីសុខភាពរបស់ពួកគេ។




*ប្រភព៖ ទំព័រគេហទំព័រផ្លូវការរបស់មូលនិធិជាតិជំនួយសង្គម បិតផ្សាយនៅថ្ងៃទី២៧ ខែមេសា ឆ្នាំ២០២៣*

### ចំនួនប្រជាជនបានចាក់វ៉ាក់សាំងកូវីដ-១៩




*ប្រភព៖ ក្រសួងសុខាភិបាលកម្ពុជា ថ្ងៃទី៣១ ខែមេសា ឆ្នាំ២០២៣*

# វិធីសាស្ត្រ និងទីតាំងផ្សារ




WFP ចាប់ផ្ដើមតាមដានតម្លៃស្បៀងអាហារ នៅតាមបណ្ដាផ្សារមួយចំនួនតាមរយៈទូរស័ព្ទ តាំងពីខែវិច្ឆិកា ឆ្នាំ២០១៩ មកម្ល៉េះ។ អ្នកសម្ភាសន៍តាមទូរស័ព្ទ ដែលបានទទួលការបណ្ដុះបណ្ដាលច្បាស់លាស់បានទំនាក់ទំនងទៅកាន់អាជីវករនានា រៀងរាល់មួយខែម្ដង ដើម្បីប្រមូលតម្លៃទំនិញចំនួន៣៦ប្រភេទ ក្នុងផ្សារចំនួន១៩ នៅទីប្រជុំជន និងជនបទនៃខេត្តបាត់ដំបង កំពង់ឆ្នាំង កំពង់ធំ ឧត្តរមានជ័យ សៀមរាប ព្រះវិហារ និងស្ទឹងត្រែង។

នៅក្រោមកិច្ចសហការជាមួយការិយាល័យទីផ្សារកសិកម្ម នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅខែមីនា ឆ្នាំ២០២០ WFP បានអង្កេតតម្លៃទីផ្សារនៅក្នុងផ្សារចំនួន៣១បន្ថែមទៀត ដើម្បីប្រមូលទិន្នន័យមូលដ្ឋាន និងដើម្បីពង្រីកចំនួនផ្សារគ្របដណ្ដប់។ យើងបានប្រមូលតម្លៃស្បៀងចំនួន១៦ប្រភេទ និងព័ត៌មានពីដំណើរការរបស់ផ្សារទាំងនោះផងដែរ។

ចាប់ពីពាក់កណ្ដាលខែមេសាឆ្នាំ២០២០មក WFP បានពង្រីកការតាមដានតម្លៃទីផ្សារតាមរយៈទូរស័ព្ទក្នុងផ្សារចំនួន៤៥ ហើយក៏បានបង្កើនចំនួនប្រមូលទិន្នន័យ ២ដងក្នុងមួយខែផងដែរ (ឧ. សប្ដាហ៍ទី១ និងទី៣នៃខែនីមួយៗ)។

នៅពាក់កណ្ដាលខែកញ្ញា ឆ្នាំ២០២២ WFP បន្ថែមទំនិញជាស្បៀងអាហារ និងមិនមែនស្បៀងអាហារចំនួន ១៥ (មើលឧបសម្ព័ន្ធ) និងពង្រីកផ្សារគ្របដណ្ដប់ដល់ ៥៦ ផ្សារ។

# ឧបសម្ព័ន្ធទី១៖ បម្រែបម្រួលតម្លៃលក់រាយ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 2,140 | → 0.7% | → 2.5% | → 3.7% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 11,156 | → 3.5% | → 3.6% | ↑ 11.1% |
| ២.២ ត្រីប្រា(រស់) | Kg | 7,433 | → 2.7% | ↑ 8.8% | ↑ 12.2% |
| ២.៣ ត្រីអណ្តែង(រស់) | Kg | 8,090 | → 4.2% | ↑ 5.8% | ↑ 10.1% |
| ២.៤ ត្រីងៀត(ផ្ទក់) | Kg | 27,130 | ↑ 5.4% | → 3.3% | ↑ 8.0% |
| ២.៥ ប្រហុក | Kg | 9,787 | → 0.5% | ↑ 9.1% | ● |
| ៣.១ សាច់ជ្រូកពាជាន់ | Kg | 16,343 | → 2.8% | → -0.4% | ↓ -20.1% |
| ៣.២ សាច់គោឃារ | Kg | 19,331 | → 1.4% | → -1.0% | ● |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 14,244 | ↑ 5.1% | → 0.3% | ● |
| ៤.១ ស៊ុតទា | 10 eggs | 5,333 | → 0.7% | → -0.6% | ↓ -5.5% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 6,882 | → 1.7% | → -0.9% | → -1.1% |
| ៥.១ ប្រេងឆា | 5 litres | 27,996 | → -2.2% | ↓ -6.1% | ↓ -19.4% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 1,268 | → 1.3% | → -5.0% | → 2.7% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 3,423 | → 0.0% | → 1.2% | ● |
| ៧.១ សណ្តែកដី* | Kg | 10,011 | → -0.9% | → 0.5% | → 4.9% |
| ៧.២ សណ្តែកសៀង | Kg | 5,628 | ↑ 8.6% | → 4.6% | ● |
| ៧.៣ សណ្តែកខៀវ | Kg | 6,104 | → 0.5% | → 3.1% | ● |
| ៨.១ ត្រកួន | Kg | 2,765 | ↓ -5.7% | ↓ -13.3% | ↓ -7.9% |
| ៨.២ ការ៉ុត* | Kg | 3,419 | → -0.4% | → -2.2% | ↓ -6.4% |
| ៨.៣ ស្លឹកបាស* | Kg | 4,855 | → -1.2% | → -2.8% | ↑ 9.4% |
| ៨.៤ ស្លឹកម្រុំ* | Kg | 5,177 | → 3.7% | → 2.0% | → -2.3% |
| ៨.៥ ម្ទេសក្រញាញ់* | Kg | 4,335 | ↑ 14.0% | ↑ 23.8% | → 3.2% |
| ៨.៦ ម្ទេសតឿ* | Kg | 4,264 | ↑ 15.7% | ↑ 25.3% | ↑ 9.8% |
| ៨.៧ ម្ទេសចង្កឹះ | Kg | 3,968 | ↑ 13.9% | ↑ 34.2% | ↑ 10.5% |
| ៨.៨ ម្ទេសខៀវ* | Kg | 3,986 | ↑ 15.1% | ↑ 25.5% | ↑ 24.4% |
| ៨.៩ ខ្ទឹមដូង* | Kg | 3,802 | ↓ -13.4% | ↓ -11.2% | ↑ 5.5% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្លឹកងប់* | Kg | 5,588 | ↑ 7.2% | ↑ 6.0% | ↓ -10.1% |
| ៨.១១ ត្រយូងល្ពៅ* | Kg | 4,228 | ↓ -9.6% | ↓ -11.9% | ↓ -12.5% |
| ៨.១២ ផ្លែល្ពៅ* | Kg | 2,546 | ↓ -11.0% | ↓ -11.7% | ↑ 12.3% |
| ៨.១៣ ឃ្លោក* | Kg | 1,875 | ↓ -50.0% | ● | ↑ 12.5% |
| ៨.១៤ ត្រឡាច | Kg | 2,718 | → 2.0% | ↑ 19.0% | ↑ 27.9% |
| ៨.១៥ ត្រប់វែង | Kg | 3,089 | ↓ -5.7% | ↓ -18.2% | ↑ 15.3% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 3,083 | → -4.5% | ↓ -16.9% | → 4.5% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 3,598 | → -2.0% | ↓ -16.7% | ↑ 7.1% |
| ៨.១៨ននោងមូល | Kg | 2,810 | → -3.8% | ↓ -6.7% | ↑ 18.4% |
| ៨.១៩ ននោងជ្រុង* | Kg | 2,721 | ↓ -16.0% | ↓ -9.9% | ↑ 21.2% |
| ៨.២០ ល្ហុងខ្ចី* | Kg | 2,377 | ↑ 24.2% | ↑ 39.7% | ↑ 64.2% |
| ៨.២១ សណ្តែកកួរ | Kg | 4,708 | ↑ 18.2% | ↑ 23.6% | ↑ 48.6% |
| ៨.២២ ត្រយូងចេក* | Kg | 2,603 | ↑ 19.5% | ↑ 15.4% | ↑ 23.3% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 5,726 | ↑ 8.3% | → 1.3% | ↓ -9.1% |
| ៨.២៤ ដើមខាត់ណា* | Kg | 4,879 | ↑ 7.8% | ↑ 6.8% | → 2.8% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 3,205 | → 1.2% | → 1.7% | ↑ 31.8% |
| ៨.២៦ ខ្ទឹមសរ | Kg | 5,573 | ↑ 5.5% | ↑ 8.2% | ● |
| ៨.២៧ អំពិលទុំ (មានគ្រាប់) | Kg | 3,749 | → -2.6% | ↓ -8.8% | ● |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 2,358 | ↑ 8.1% | ↑ 9.4% | ● |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 1,175 | ↓ -32.9% | ↓ -62.9% | ● |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,865 | ↑ 9.4% | ↑ 13.2% | ● |
| ១១.១ កូកាកូឡា | 330 ml | 2,038 | → 2.4% | → 2.5% | ● |
| ៧.១ សាំងធម្មតា | litre | 4,288 | → -0.2% | → 1.3% | ● |
| ៧.២ ម៉ាស៊ូត | litre | 4,130 | → -1.7% | ↓ -8.7% | ● |
| ៨.១ ជីអ៊ុយរ៉េ | Kg | 2,930 | ↓ -9.7% | ↓ -16.3% | ● |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្តែង ខ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្តល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- ● គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី២៖ បម្រែបម្រួលតម្លៃលក់ដុំ

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ១.១ អង្ករចម្រុះ | Kg | 1,962 | → -0.4% | → 1.1% | → 2.3% |
| ២.១ ត្រីផ្ទក់(រស់) | Kg | 9,800 | → -1.5% | → -0.1% | ↑ 7.5% |
| ២.២ ត្រីប្រា(រស់) | Kg | 6,513 | → 2.8% | ↑ 6.9% | ↑ 8.0% |
| ២.៣ ត្រីអណ្ដែង(រស់) | Kg | 7,100 | → 3.0% | → 3.1% | ↑ 5.3% |
| ២.៤ ត្រីងៀត(ផ្ទក់) | Kg | 25,167 | ↑ 6.2% | → 3.8% | ↑ 10.5% |
| ២.៥ ប្រហុក | Kg | 8,617 | → 1.8% | ↑ 8.8% | ● |
| ៣.១ សាច់ជ្រូកពាជាន់ | Kg | 14,921 | → 3.2% | → -0.5% | ↓ -21.2% |
| ៣.២ សាច់គោយារ | Kg | 17,653 | → 3.9% | → -0.7% | ● |
| ៣.៣ សាច់មាន់ (បីសាសន៍) | Kg | 13,144 | ↑ 5.5% | → 0.3% | ● |
| ៤.១ ស៊ុតទា | 10 eggs | 4,833 | → -0.2% | → -0.8% | ↓ -8.5% |
| ៤.២ ស៊ុតទាប្រៃ | 10 eggs | 6,272 | → 0.5% | → -2.2% | → -2.9% |
| ៥.១ ប្រេងឆា | 5 litres | 27,004 | → -2.0% | ↓ -6.3% | ↓ -20.0% |
| ៦.១ អំបិលម៉ត់អ៊ីយូត | Kg | 1,005 | → 1.1% | ↓ -8.3% | → -3.0% |
| ៦.២ ទឹកត្រី (រូបបង្គងប៉ាក) | 730 ml | 3,115 | → 2.0% | → 3.1% | ● |
| ៧.១ សណ្ដែកដី* | Kg | 9,076 | → -2.2% | → -1.6% | → 4.9% |
| ៧.២ សណ្ដែកសៀង | Kg | 5,206 | ↑ 14.9% | → 3.6% | ● |
| ៧.៣ សណ្ដែកខៀវ | Kg | 5,722 | → 2.1% | ↑ 5.4% | ● |
| ៨.១ ត្រកួន | Kg | 2,158 | ↓ -5.5% | ↓ -19.3% | ↓ -16.3% |
| ៨.២ ការ៉ុត* | Kg | 2,815 | → 2.8% | → -3.5% | ↓ -9.3% |
| ៨.៣ ស្ពៃក្ដោប* | Kg | 3,657 | → -3.7% | ↓ -9.3% | → 3.3% |
| ៨.៤ ស្លឹកម្រុំ* | Kg | 3,913 | ↑ 11.6% | → -0.5% | ↓ -19.3% |
| ៨.៥ ម្ទេសក្រញាញ់* | Kg | 3,472 | ↑ 13.5% | ↑ 23.3% | → -1.8% |
| ៨.៦ ម្ទេសតឿ* | Kg | 3,374 | ↑ 13.3% | ↑ 24.8% | → 2.0% |
| ៨.៧ ម្ទេសចង្កឹះ | Kg | 3,223 | ↑ 17.0% | ↑ 38.9% | ↑ 7.5% |
| ៨.៨ ម្ទេសខៀវ* | Kg | 3,185 | ↑ 15.6% | ↑ 30.0% | ↑ 21.5% |
| ៨.៩ ផ្ទីដូង* | Kg | 3,165 | ↓ -7.9% | → -4.1% | ↑ 10.8% |

| ស្បៀងអាហារ | ខ្នាត | តម្លៃមធ្យមប្រចាំខែបច្ចុប្បន្ន | បម្រែបម្រួលតម្លៃធៀបនឹង១ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង៣ខែមុន | បម្រែបម្រួលតម្លៃធៀបនឹង១ឆ្នាំមុន |
|---|---|---|---|---|---|
| ៨.១០ ស្លឹកងប់* | Kg | 4,084 | ↑ 5.6% | → -1.5% | ↓ -17.1% |
| ៨.១១ ត្រយូងល្ពៅ* | Kg | 2,862 | ↓ -22.3% | ↓ -22.9% | ↓ -35.2% |
| ៨.១២ ផ្លែល្ពៅ* | Kg | 2,000 | ↓ -8.9% | ↓ -16.6% | ↑ 11.4% |
| ៨.១៣ ឃ្លោក* | Kg | 1,667 | ↓ -44.4% | ● | ↑ 25.0% |
| ៨.១៤ ត្រឡាច | Kg | 2,042 | → 1.1% | ↑ 14.3% | ↑ 20.5% |
| ៨.១៥ ត្រប់វែង | Kg | 2,402 | ↓ -10.1% | ↓ -22.9% | ↑ 9.2% |
| ៨.១៦ ត្រប់ស្រួយ* | Kg | 2,405 | ↓ -5.6% | ↓ -22.3% | → -3.5% |
| ៨.១៧ ប៉េងប៉ោះ* | Kg | 2,751 | → -4.4% | ↓ -25.0% | → -4.1% |
| ៨.១៨ ននោងមូល | Kg | 2,115 | ↓ -5.9% | ↓ -9.4% | ↑ 6.5% |
| ៨.១៩ ននោងជ្រុង* | Kg | 2,059 | ↓ -16.6% | ↓ -11.3% | ↑ 8.7% |
| ៨.២០ ល្ហុងខ្ចី* | Kg | 1,831 | ↑ 23.7% | ↑ 38.2% | ↑ 56.1% |
| ៨.២១ សណ្ដែកកួរ | Kg | 3,863 | ↑ 18.9% | ↑ 20.7% | ↑ 44.4% |
| ៨.២២ ត្រយូងចេក* | Kg | 2,041 | ↑ 18.9% | ↑ 11.2% | ↑ 12.0% |
| ៨.២៣ ផ្កាខាត់ណា* | Kg | 4,892 | ↑ 8.1% | → -0.1% | ↓ -15.5% |
| ៨.២៤ ដើមខាត់ណា* | Kg | 4,001 | ↑ 6.4% | → 4.1% | → -4.0% |
| ៨.២៥ ដំឡូងពណ៌លឿង* | Kg | 2,555 | → -3.8% | → -1.7% | ↑ 22.4% |
| ៨.២៦ ខ្ទឹមសរ | Kg | 4,774 | → 2.8% | → 4.2% | ● |
| ៨.២៧ អំពិលទុំ (មានគ្រាប់) | Kg | 3,019 | ↓ -6.0% | ↓ -15.4% | ● |
| ៩.១ ចេកណាំវ៉ាទុំ | Kg | 1,828 | → 3.1% | → 4.1% | ● |
| ៩.២ ស្វាយកែវរមៀតទុំ | Kg | 825 | ↓ -8.3% | ↓ -69.8% | ● |
| ១០.១ ទឹកដោះគោស្រស់ | 140 ml | 1,594 | ↑ 7.9% | ↑ 6.5% | ● |
| ១១.១ កូកាកូឡា | 330 ml | 1,590 | → 4.0% | → 0.8% | ● |
| ៧.១ សាំងធម្មតា | litre | 4,034 | → -1.2% | → -0.5% | ● |
| ៧.២ ម៉ាស៊ូត | litre | 3,973 | → -2.7% | ↓ -10.1% | ● |
| ៨.១ ជីអ៊ុយរ៉េ | Kg | 2,539 | ↓ -8.3% | ↓ -16.7% | ● |

*សម្គាល់៖ ទិន្នន័យនិងបម្រែបម្រួលតម្លៃ ដែលបានរាយការណ៍គឺជាតម្លៃជាក់ស្ដែង ខ. តម្លៃរាយការណ៍ពីទីផ្សារផ្ទាល់។*

** តម្លៃនៃស្បៀងអាហារទាំងនេះ ត្រូវបានប្រមូលពីផ្សារក្នុងខេត្តដែលអនុវត្តកម្មវិធីផ្ដល់អាហារលេតាមសាលារៀនដោយប្រើប្រាស់កសិផលពីសហគមន៍។*

ទិសដៅបម្រែបម្រួលធៀបជាមួយខែមុន និងឆ្នាំមុន៖

- ↑ កើនឡើង នៅពេលភាគរយបម្រែបម្រួលច្រើនជាង ៥%
- → ថេរ នៅពេលភាគរយបម្រែបម្រួលនៅចន្លោះពី ៥% និង -៥%
- ↓ ថយចុះ នៅពេលភាគរយបម្រែបម្រួលតិចជាង -៥%
- ● គ្មានតម្លៃកត់ត្រា

# ឧបសម្ព័ន្ធទី៣៖ តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន

ការគណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន ដែលបង្ហាញនៅក្នុងរបាយការណ៍នេះ ផ្អែកចម្បងលើការវិភាគកញ្ចប់ចំណាយអប្បបរមា (MEB) នៅប្រទេសកម្ពុជា។ ដើម្បីរៀបចំកញ្ចប់អាហារសម្រាប់ការវិភាគនេះ ក្រុមគ្រួសារគោលត្រូវបានវិភាគចេញពីទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៥ ផ្អែកលើលក្ខខណ្ឌដូចខាងក្រោម៖

i. គ្រួសារដែលមានការចំណាយប្រចាំខែនៅចន្លោះបញ្ចភាគទី២ និងទី៤

ii. គ្រួសារមានសន្តិសុខស្បៀងគ្រប់គ្រាន់ (ពិន្ទុកម្រិតទទួលទានអាហារអាចទទួលយកបាន)

iii. គ្រួសារមិនបានប្រើប្រាស់យុទ្ធសាស្ត្រអវិជ្ជមានដើម្បីដោះស្រាយបញ្ហាខ្វះស្បៀង។

កញ្ចប់ស្បៀងអាហារសម្រាប់ក្រុមគ្រួសារគោលនេះ ត្រូវបានបង្កើតឡើងដើម្បីស្វែងយល់អំពីទម្រង់នៃការទទួលទានអាហារ ដែលសមស្របទៅនឹងអាហាររបស់គ្រួសារនីមួយៗគួរទទួលទាន ដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម។[1] ដូច្នេះ ស្បៀងអាហារជាក់លាក់ត្រូវបានកំណត់ ដើម្បីជាតំណាងឱ្យក្រុមអាហារនានាដែលមាននៅក្នុងផ្នែកការចំណាយលើស្បៀងអាហារ (សូមមើលតារាងទី២សម្រាប់បញ្ជីស្បៀងអាហារពេញ)។ ថាមពលគីឡូកាឡូរី និងបរិមាណស្បៀងត្រូវបានវិភាគចេញពីទិន្នន័យការចំណាយរបស់អង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៥ ដើម្បីកំណត់កម្រិតកាឡូរីមួយកញ្ចប់សម្រាប់មនុស្សម្នាក់ គួរទទួលទានដើម្បីរស់នៅប្រកបដោយសុខភាពល្អ និងជីវិតសកម្ម តាមទម្រង់សិទ្ធិទទួលបានជាមូលដ្ឋាន។

**តារាង២៖ សង្ខេបធាតុចូលសម្រាប់គណនាតម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាន**

| ក្រុមអាហារ[2] | ប្រភេទអាហារ[3] | ប្រភេទអាហារ[4] | គីឡូកាឡូរី/ម្នាក់/ថ្ងៃ[2] | ក្រាម/ម្នាក់/ថ្ងៃ[2] | រៀល/ក្រាម[4] | រៀល/ម្នាក់/ខែ[4] |
|---|---|---|---|---|---|---|
| Cereals | Rice | 1.1. អង្ករចម្រុះ/ Mixed Rice | 1,470.23 | 413.0 | 2.1 | 26,884 |
| Fish | Mud fish | 2.1. ត្រីផ្ទក់(រស់)/ Snakehead fish (Live) | 76.47 | 91.0 | 11.2 | 30,888 |
| Meat | Pork | 3.1. សាច់ជ្រូកពជាន់/ 3-layer pork/Pork with fat | 77.75 | 40.7 | 16.3 | 20,234 |
| Egg | Duck egg | 4.1. ស៊ុតទា/Duck egg | 21.92 | 11.8 | 8.5 | 3,075 |
| Diary | Milk | ---NA--- | 7 | 12.0 | --- | --- |
| Oil | Vegetable oil | 5.1. ប្រេងឆា/ Vegetable Oil: Saji ឬ Mongsay ឬ Cailan | 115.36 | 12.8 | 6.2 | 2,401 |
| Veg | Morning Glory | 8.1. ត្រកួន/ Morning glory | 34.76 | 231.7 | 2.8 | 19,493 |
| Tuber | Sweet Potato | 8.25. ដំឡូងផ្កាពណ៌លឿង/ Orange-flesh Sweet Potatoes | 19.21 | 19.6 | 3.2 | 1,911 |
| Pulses | Soybean/green bean | ---NA--- | 8 | 21.6 | --- | --- |
| Fruit | Banana | ---NA--- | 91 | 96.4 | --- | --- |
| | | **Total** | **1,937** | **950.6** | **---** | **104,887** |

ប្រភេទស្បៀងអាហារមួយចំនួនមិនត្រូវបានតាមដានដោយប្រព័ន្ធតាមដានទីផ្សាររបស់ WFP ដូច្នេះប្រភេទស្បៀងអាហារជាក់លាក់នោះមិនត្រូវបានរាប់បញ្ចូលនៅក្នុងកញ្ចប់ស្បៀងអាហារ ដែលបានតាមដាននៅក្នុងរបាយការណ៍នេះទេ។ ទោះជាយ៉ាងណា ទម្រង់នៃការបរិភោគស្បៀងអាហារនីមួយៗ (ទម្ងន់ គិតជា ក្រាម/ម្នាក់/ថ្ងៃ) អាចតំណាងឱ្យតម្លៃនៃម្ហូបអាហារប្រកបដោយអាហារូបត្ថម្ភ នៅក្នុងប្រទេសកម្ពុជា។

*[1] តម្លៃនៃកញ្ចប់ស្បៀងអាហារមូលដ្ឋាននៅក្នុងរបាយការណ៍បច្ចុប្បន្នភាពទីផ្សារនេះ មិនដូចគ្នា ជាមួយតម្លៃនៃកញ្ចប់ស្បៀងអាហាររបស់វិទ្យាស្ថានជាតិស្ថិតិនៃក្រសួងផែនការប្រើសម្រាប់គណនាបន្ទាត់ភាពក្រីក្រថ្នាក់ជាតិឡើង។ កញ្ចប់ស្បៀងអាហារនៅក្នុងរបាយការណ៍នេះត្រូវបានគណនាដោយប្រើវិធីសាស្ត្រផ្សេង ហើយមានប្រយោជន៍ជាចម្បងសម្រាប់តម្លៃស្បៀងអាហារ។*

*[2] ការអង្កេតសេដ្ឋកិច្ច សង្គមកិច្ច ឆ្នាំ២០១៥ វិទ្យាស្ថានជាតិស្ថិតិ ប្រទេសកម្ពុជា។*

*[3] ការប៉ាន់ប្រមាណពីតម្លាតនៃការចំណាយ និងកញ្ចប់ចំណាយអប្បបរមានៅកម្ពុជា។ របាយការណ៍បច្ចេកទេស ខែមិថុនាឆ្នាំ២០២០ WFP ប្រចាំប្រទេសកម្ពុជា។*

*[4] បច្ចុប្បន្នភាពទីផ្សារ និងការតាមដានតាមរដូវកាល ខែមេសា ឆ្នាំ២០២៣ WFP ប្រចាំប្រទេសកម្ពុជា។*